# ការរក្សាសុវត្ថិភាព នៅកៀករថយន្តក្រុង

massDOT
Massachusetts Department of Transportation

MASSACHUSETTS Safe Routes to School
MASS.GOV/SAFE-ROUTES-TO-SCHOOL

រថយន្តសាលានិងរថយន្តក្រុងត្រូវបានប្រើប្រាស់ជាមធ្យោបាយដឹកជញ្ជូនសាធារណៈសម្រាប់កូនសិស្សជាច្រើននាក់។នៅពេលទិន្នន័យបង្ហាញថាវិធីដែលមានសុវត្ថិភាពបំផុតដើម្បីទៅដល់និងចេញពីសាលារៀនគឺជារថយន្តសាលា ប្រភេទរថយន្តក្រុងឬរថយន្តតួរីសនីមួយៗមានលក្ខណៈពិសេស។ ការយល់ដឹងពីរបៀបទុកគន្លងផ្លូវឲ្យរថយន្តក្រុងធ្វើចរាចរណ៍និងរបៀបដែលរថយន្តក្រុងឈប់ញឹកញាប់ធ្វើឲ្យការធ្វើដំណើរមានសុវត្ថិភាពដល់កូនសិស្សទាំងអស់គ្នា។

## គោលការណ៍ណែនាំអំពីសុវត្ថិភាពសម្រាប់ការបើកបរនៅកៀករថយន្តក្រុងទាំងអស់

### 1 ចៀសវាងបើកបរក្នុងគន្លងផ្លូវរថយន្តក្រុង។

ការបែងចែកគន្លងផ្លូវរថយន្តក្រុង មិនថានៅសាលារៀនឬនៅលើផ្លូវឡើយ ជួយធ្វើឲ្យការធ្វើដំណើរតាមរថយន្តក្រុងមានសុវត្ថិភាពនិងមានប្រសិទ្ធភាពជាងមុនសម្រាប់អ្នកដំណើរ អ្នកថ្មើរជើង និងអ្នកធ្វើដំណើរនៅតាមដងផ្លូវផ្សេងទៀត។

### 2 យកចិត្តទុកដាក់ចំពោះអ្នកដំណើរដែលឡើងជិះ ឬចុះពីរថយន្តក្រុង។

បន្ទាប់ពីមានអ្នកចុះពីរថយន្តក្រុង ពួកគេក្លាយជាអ្នកថ្មើរជើង។ ច្បាប់ថ្មីស្តីពី**អ្នកប្រើប្រាស់ដែលងាយរងគ្រោះ**របស់រដ្ឋម៉ាសាឈូសេតតម្រូវឲ្យអ្នកបើកបរយានយន្តត្រូវរក្សាចម្ងាយបួនហ្វីតដើម្បីវាំងជែងអ្នកថ្មើរជើងនិងអ្នកជិះកង់។[1]




### 3 ត្រៀមឈប់ពីក្រោយរថយន្តក្រុងនៅផ្លូវរថភ្លើងឆ្លងកាត់។

រថយន្តក្រុងទាំងអស់ ដែលមាននិងគ្មានអ្នកដំណើរត្រូវតែបើកឲ្យដល់ចំណតនៅផ្លូវរថភ្លើងឆ្លងកាត់ទាំងអស់ ប្រសិនបើអ្នកបើកបរបើកទ្វារអ្នកដំណើរដើម្បីពិនិត្យមើលរថភ្លើងដែលមកជិតដល់។[2]




### 4 កុំបើកទៅកៀកពីក្រោយរថយន្តគេពេក។ ត្រូវរក្សាចម្ងាយសុវត្ថិភាពនិងត្រៀមឈប់ញឹកញាប់។

រថយន្តក្រុងត្រូវការគម្លាតបន្ថែមទៀតដើម្បីដំណើរការដោយសុវត្ថិភាព។ ត្រូវរក្សាចម្ងាយឲ្យបានគ្រប់គ្រាន់ដើម្បីត្រៀមឈប់ញឹកញាប់។

### 5 ផ្តល់គម្លាតសម្រាប់ឲ្យរថយន្តក្រុងបើកចេញពីចំណតដោយសុវត្ថិភាពនិងបើកចូលគន្លងចរាចរណ៍វិញ។

ការយោគយល់របស់អ្នកក្នុងការផ្តល់ចំណតដល់រថយន្តក្រុងធ្វើឲ្យមានលំហូរចរាចរណ៍កាន់តែរលូននិងជួយឲ្យរថយន្តក្រុងបើកបរទាន់ម៉ោង ធ្វើដំណើរ។[3]



### 6 ហាមវ៉ាជែងរថយន្តក្រុងពីខាងស្តាំ។[4]

រថយន្តធុនធំច្រើនតែបត់ឆ្វេងមុននឹងវង់បត់ស្តាំ ហើយប្រសិនបើអ្នកនៅក្បែររថយន្តដឹកទំនិញឬរថយន្តក្រុង រថយន្តទាំងនោះមិនអាចមើលឃើញអ្នកឡើយ។

### 7 អនុវត្តការអត់ធ្មត់។

អ្នកដំណើរតាមរថយន្តសាលានិងរថយន្តក្រុង មានតាំងពីក្មេងរហូតដល់មនុស្សចាស់។ ត្រូវអត់ធ្មត់ដើម្បីឲ្យអ្នកទាំងអស់នោះអាចឡើងជិះឬចុះពីរថយន្តដោយសុវត្ថិភាព។

[1] https://malegislature.gov/Laws/GeneralLaws/PartI/TitleXIV/Chapter90/Section14
[2] https://malegislature.gov/Laws/GeneralLaws/PartI/TitleXIV/Chapter90/Section15
[3] https://www.mass.gov/files/documents/2018/03/21/Drivers_Manual.pdf
[4] https://www.mass.gov/files/documents/2018/03/21/Drivers_Manual.pdf
[5] https://malegislature.gov/Laws/GeneralLaws/PartI/TitleXIV/Chapter90/Section14
[6] https://malegislature.gov/Laws/GeneralLaws/PartI/TitleXIV/Chapter90/Section14
[7] លើកលែងតែបើកបរនៅលើផ្លូវហាយវេ
https://malegislature.gov/Laws/GeneralLaws/PartI/TitleXIV/Chapter90/Section17

## រថយន្តសាលា និងច្បាប់

### ការបើកបរកៀករថយន្តសាលាតម្រូវឲ្យមានការយកចិត្តទុកដាក់បន្ថែមទៀត!

#### ឈប់នៅពេលមានភ្លើងលោតភ្លឹបភ្លែត។




វាជាច្បាប់!យានយន្តទាំងឡាយត្រូវតែឈប់នៅពេលដែលរថយន្តសាលាឬរថយន្តតួរីសលោតភ្លើងភ្លឹបភ្លែតហើយចេញផ្លាកសញ្ញាឈប់។ ការបំពានត្រូវផាកពិន័យចំនួន $250 និងអាចបណ្តាលឲ្យមានការព្យួរអាជ្ញាប័ណ្ណ។[5]

#### កុំជិះទៅកៀកនឹងរថយន្តក្រុងពេក។

វាជាច្បាប់! នៅរដ្ឋម៉ាសាឈូសេត យានយន្តត្រូវតែស្ថិតនៅចម្ងាយពីគ្នាចំនួន 100 ហ្វីតពីខាងក្រោយរថយន្តសាលា។[6] ចម្ងាយបន្ថែមនេះអនុញ្ញាតឲ្យអ្នកបើកបររថយន្តសាលាមើលឃើញកូនសិស្សដែលឡើងជិះនិងចុះពីរថយន្តសាលា ។

KEEP BACK 100 FEET

#### គោរពល្បឿនកំណត់នៅតំបន់មានសាលារៀន។




វាជាច្បាប់! ល្បឿនកំណត់នៅតំបន់មានសាលារៀនកំណត់ត្រឹម 20 mph។[7]

## រថយន្តសាលា ការបែងចែកសុវត្ថិភាព

- មានតែរថយន្តសាលា រួមជាមួយរថយន្តពន្លត់អគ្គីភ័យ រថយន្តប៉ូលីសនិងរថយន្តសង្គ្រោះបន្ទាន់ប៉ុណ្ណោះ អាចបញ្ឈប់ចរាចរណ៍បាន។
- រថយន្តសាលាគឺជាយានយន្តតែមួយគត់ដែលរង់ចាំកូនសិស្សឆ្លងផ្លូវដោយសុវត្ថិភាព។នៅពេលរថយន្តសាលាឈប់ដោយមានលោតភ្លើងភ្លឹបភ្លែត គឺនៅមានវត្តមានកូនសិស្សហើយកូនសិស្សមិនទាន់ចុះពីរថយន្តឬមិនទាន់បានឆ្លងផ្លូវដោយសុវត្ថិភាពឡើយ។

# រក្សាសុវត្ថិភាពដោយចៀសវាងតំបន់មានគ្រោះថ្នាក់

ចំណុចមើលមិនឃើញដែលមាននៅជុំវិញរថយន្តធុនធំត្រូវបានស្គាល់ថាជាតំបន់មានគ្រោះថ្នាក់។ នេះជាកន្លែងដែលការរងរបួសភាគច្រើនកើតឡើងទាក់ទងនឹងយានយន្ត។ ដោយសារតែអ្នកបើកបរមិនអាចមើលឃើញអ្នកនៅតំបន់មានគ្រោះថ្នាក់ ត្រូវប្រុងប្រយ័ត្នត្រង់ចំណុចនេះមិនថាអ្នកជាអ្នកបើកបរ អ្នកដើរ ឬអ្នករត់លេងឡើយ។




## រថយន្តនៅពីក្រោយរថយន្ត

នៅតំបន់មានសាលារៀន ការវ៉ាជែងយានយន្តផ្សេងទៀតជាការខុសច្បាប់។[10]

## ការចេញផ្លាកសញ្ញាឈប់

អ្នកបើកបរយានយន្តត្រូវឈប់នៅពេលរថយន្តសាលាលោតភ្លើងភ្លឹបភ្លែត។[8]

## រថយន្តនៅពីក្រោយរថយន្តក្រុង

ត្រូវរក្សាចម្ងាយ 100 ហ្វីតពីក្រោយរថយន្តសាលាតាមច្បាប់តម្រូវ។[9]

## អ្នកជិះកង់

ទុកផ្លូវឲ្យរថយន្តក្រុងធ្វើដំណើរផង។ ចៀសវាងការវ៉ាជែងរថយន្តក្រុងពីខាងស្តាំនិងត្រូវមើលរថយន្តដែលបើកមកពីខាងឆ្វេងដៃអ្នក។ ត្រូវរង់ចាំឲ្យរថយន្តក្រុងបើកចូលគន្លងផ្លូវធ្វើដំណើរវិញជាជាងជិះវ៉ាជែង។

## កញ្ចក់មើលចំហៀង

ត្រូវប្រាកដថាអ្នកអាចមើលឃើញកញ្ចក់មើលចំហៀងរបស់រថយន្តក្រុង។អ្នកបើករថយន្តក្រុងមិនអាចឃើញអ្នកបានឡើយប្រសិនបើអ្នកមិនអាចមើលឃើញពួកគេ។

## ចំណតរថយន្តសាលា

ត្រូវអត់ធ្មត់និងចេះសង្កេតនៅពេលកំពុងរង់ចាំរថយន្តក្រុងរបស់អ្នក។ កូនសិស្សត្រូវរង់ចាំរហូតដល់អ្នកបើករថយន្តសាលាឈប់ដើម្បីបញ្ជាក់ថាវាមានសុវត្ថិភាពក្នុងការឆ្លងផ្លូវ។ ទុកឲ្យរថយន្តក្រុងបើកមករកអ្នកកុំរត់ទៅរករថយន្តក្រុងដែលកំពុងបើក។

## អ្នកថ្មើរជើង

គេចពីតំបន់មានគ្រោះថ្នាក់បំផុតបើអ្នកបើកបររថយន្តក្រុងមិនអាចមើលឃើញនរណាម្នាក់ដែលដើរកាត់ពីមុខរថយន្តក្រុងរបស់ពួកគេដោយផ្ទាល់បាន។ មុនឆ្លងផ្លូវ ត្រូវបោះ "ជំហានឲ្យវែង" ចំនួនប្រាំជំហាននៅលើចិញ្ចើមផ្លូវទៅខាងមុខរថយន្តក្រុង។ ត្រូវរង់ចាំអ្នកបើករថយន្តសាលាផ្តល់សញ្ញាថាវាមានសុវត្ថិភាពក្នុងការឆ្លងផ្លូវ។

[8] https://malegislature.gov/Laws/GeneralLaws/PartI/TitleXIV/Chapter90/Section14
[9] https://malegislature.gov/Laws/GeneralLaws/PartI/TitleXIV/Chapter90/Section14
[10] https://malegislature.gov/Laws/GeneralLaws/PartI/TitleXIV/Chapter90/Section17

កម្មវិធី Safe Routes to School ( SRTS ) គឺជាកម្មវិធីដែលផ្តល់មូលនិធិដោយសហព័ន្ធដែលផ្តល់ដោយនាយកដ្ឋានដឹកជញ្ជូនរបស់រដ្ឋម៉ាសាឈូសេត។ កម្មវិធី SRTS ដំណើរការដើម្បីបង្កើនការដើរការជិះកង់និងការរត់លេងដោយសុវត្ថិភាពក្នុងចំណោមកូនសិស្សសាលារដ្ឋពីថ្នាក់មត្តេយ្យដល់ថ្នាក់ទី12ដោយប្រើវិធីសាស្ត្រដែលផ្តោតលើសហគមន៍ដែលសហការគ្នាធ្វើការបំពេញចន្លោះខ្វះខាតរវាងសុខភាពនិងការដឹកជញ្ជូន។ សូមស្វែងយល់បន្ថែមតាមរយៈ៖ www.mass.gov/safe-routes-to-school

massDOT
Massachusetts Department of Transportation

MASSACHUSETTS
Safe Routes to School
MASS.GOV/SAFE-ROUTES-TO-SCHOOL